# សង្គមស៊ីវិលថ្កោលទោសការចោទប្រកាន់នានាលើអ្នកការពារសិទ្ធិមនុស្ស

ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦

យើងខ្ញុំ ជាក្រុមអង្គការសង្គមស៊ីវិលដែលមានរាយនាមដូចខាងក្រោម មានការសោកស្តាយយ៉ាងខ្លាំងចំពោះការចោទប្រកាន់និងឃាត់ខ្លួនអ្នកការពារសិទ្ធិមនុស្សមកពីក្រុមការពារសិទ្ធិមនុស្ស និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយនិងបុគ្គលិកការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ចំនួន ប្រាំមួយនាក់ ដោយហេតុផលមិនសមរម្យ។ ការដាក់គោលដៅលើបុគ្គលទាំងប្រាំមួយនាក់ (ក្នុងនោះ ប្រាំនាក់ត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការនាថ្ងៃនេះ) គឺជាភាពតានតឹងចុងក្រោយពាក់ព័ន្ធនឹងការគាបសង្កត់របស់អាជ្ញាធររដ្ឋទៅលើសង្គមស៊ីវិល ហើយជាការតបតរបស់អាជ្ញាធររដ្ឋទៅលើការគាំទ្រនៅក្នុងសំណុំរឿងរសើបរបស់អ្នកធ្វើការងារក្នុងវិស័យសិទ្ធិមនុស្ស ។

បុគ្គលិកចំនួនបួននាក់នៃសមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) រួមមានលោក នី សុខា ណៃ វង់ដា យី សុខសាន្ត និងអ្នកស្រី លឹម មុន្នី ត្រូវបានតុលាការចោទប្រកាន់នាថ្ងៃនេះពីបទសូកប៉ាន់សាក្សី តាមមាត្រា ៥៤៨ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវបានបញ្ជូនខ្លួនទៅកាន់ពន្ធនាគារ ម១ និងម២ ក្នុងរាជធានីភ្នំពេញ។ លើសពីនេះអតីតបុគ្គលិករបស់អង្គការ អាដហុក លោក នី ចរិយា ដែលទើបតែទទួលបានតំណែងជាអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងលោក សួន សាលី បុគ្គលិកការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ត្រូវបានតុលាការចោទប្រកាន់ពីបទផ្សំគំនិតសូកប៉ាន់សាក្សី (មាត្រា ២៩ និង៥៤៨ នៃក្រមព្រហ្មទណ្ឌ)។ លោក នី ចរិយា ត្រូវបានបញ្ជូនខ្លួនទៅកាន់ពន្ធនាគារ PJ។ ប្រសិនបើតុលាការផ្តន្ទាទោស អ្នកទាំងអស់នោះអាចប្រឈមមុខនឹងការជាប់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ។

អ្នកការពារសិទ្ធិមនុស្សទាំងប្រាំមួយនាក់ ត្រូវបានអង្គភាពប្រឆាំងអំពើពុករលួយកោះហៅឲ្យចូលខ្លួនឆ្លើយបំភ្លឺកាលពីសប្តាហ៍មុន ហើយ (លើកលែងតែបុគ្គលិកម្នាក់នៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាប៉ុណ្ណោះ) ត្រូវបានសាកសួរអស់រយៈពេល ៥ថ្ងៃ (ដំបូងត្រូវបានសួរដោយអង្គភាពប្រឆាំងអំពើពុករលួយ ហើយក្រោយមកដោយព្រះរាជអាជ្ញា) ពាក់ព័ន្ធនឹងលិខិតចំហដែលចុះហត្ថលេខាដោយអ្នកនាង ខុម ច័ន្ទដារាទី ហៅ ស្រីមុំ។ លិខិតចំហនេះ ត្រូវបានដាក់ ក្រោយពេលដែលអ្នកនាងកំពុងត្រូវបានសាកសួរដោយនគរបាលប្រឆាំងភេរវកម្ម និងព្រះរាជអាជ្ញា អំពីទំនាក់ទំនងស្នេហាជាមួយអនុប្រធានគណបក្សសង្គ្រោះជាតិ ក្រោយពេលដែលអង្គការ អាដហុក បានឆ្លើយតបនឹងសំណើរសុំជំនួយផ្នែកច្បាប់ និងផ្នែកសម្ភារៈរបស់អ្នកនាង ស្រីមុំ។ នៅក្នុងបរិបទនៃការជួយបែបនេះ អង្គការ អាដហុក ក៏បានផ្តល់ថវិការដល់ ស្រីមុំ ចំនួន ២០៤ ដុល្លាអាមេរិកសម្រាប់ការចាយវាយថ្លៃអាហារ និងថ្លៃធ្វើដំណើរ ដែលរួមទាំងការធ្វើដំណើរទៅចូលរួមឆ្លើយសំនួរ

របស់អាជ្ញាធរតុលាការផងដែរ។ ការផ្តល់ទឹកប្រាក់បន្តិចបន្តួចស្របតាមគោលការណ៍អង្គការទាំងនេះដល់អតិថិជន គឺសម្រាប់ការចំនាយជាមូលដ្ឋាននានា ឥឡូវនេះត្រូវបានអង្គភាពប្រឆាំងអំពើពុករលួយចោទថាជាអំពើសូកប៉ាន់ និងពុករលួយទៅវិញ។

ការដាក់គោលដៅមកលើបុគ្គលិកនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោក សួន សាលី ដោយអង្គភាពប្រឆាំងអំពើពុករលួយ និងតុលាការ គឺជាការមិនគោរពដល់អភ័យឯកសិទ្ធិការទូតក្នុងឋានៈជាបុគ្គលិកនៃអង្គការសហប្រជាជាតិ។ អង្គភាពប្រឆាំងអំពើពុករលួយ បានបដិសេធថា លោក សាលី មិនមានអភ័យឯកសិទ្ធិសម្រាប់ការពារនោះទេ។

ករណីនេះ ធ្វើឲ្យមហាជនអាចយល់ថាជាការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងស្ថាប័ននានារបស់រដ្ឋ ដើម្បីបំភិតបំភ័យ ចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌ និងដាក់ទណ្ឌកម្មដល់សកម្មភាពស្របច្បាប់របស់អ្នកការពារសិទ្ធិមនុស្ស និងសង្គមស៊ីវិល។ អង្គភាពប្រឆាំងអំពើពុករលួយ គឺជាស្ថាប័នមួយមានតួនាទីក្នុងការបំបាត់អំពើពុករលួយដែលអាចកើតមាននៅក្នុងប្រទេសកម្ពុជា ដោយមិនមែនជាស្ថាប័នមួយរបស់អាជ្ញាធររដ្ឋក្នុងការធ្វើបាបសង្គមស៊ីវិលនោះទេ។ ការចូលរួមរបស់មន្ត្រីសន្តិសុខផ្ទៃក្នុងរបស់ក្រសួងមហាផ្ទៃជាមួយមន្ត្រីអង្គភាពប្រឆាំងអំពើពុករលួយនៅក្នុងករណីនេះ គឺបង្ហាញពីការរិតត្បិតសុវត្ថិភាពនៃសកម្មភាពរបស់សង្គមស៊ីវិល។

ដោយយោងតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលរួមមានសន្ធិសញ្ញានានាដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន ប្រទេសកម្ពុជាគឺមានកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការគោរព និងការពារសិទ្ធិរបស់មនុស្សទាំងអស់តាមអំណាចយុត្តាធិការរបស់ខ្លួន រួមទាំងសិទ្ធិសេរីភាពជៀសផុតពីការដកហូតសិទ្ធិដោយមិនត្រឹមត្រូវ សេរីភាពក្នុងការបញ្ចេញមតិ ការជួបជុំ និងប្រមូលផ្តុំដោយអហិង្សា។

ណាលី ពីឡូក នាយិកាអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ បានមានប្រសាសន៍ថាៈ "បទចោទប្រកាន់ ដែលត្រូវបានចោទទៅលើអ្នកការពារសិទ្ធិមនុស្សទាំងប្រាំមួយនាក់គឺជាការចោទប្រកាន់មិនសមរម្យ ហើយធ្វើឲ្យប៉ះពាល់ដោយផ្ទាល់ទៅលើមនុស្សដែលធ្វើការងារមនុស្សធម៌ក្នុងប្រទេសកម្ពុជា"។ សកម្មភាពនេះ គឺជាការប៉ះពាល់យ៉ាងខ្លាំងក្លាលើសង្គមស៊ីវិល និងអ្នកដែលធ្វើការងារដើម្បីលើកកំពស់សិទ្ធិមនុស្ស ហើយអាចបានបង្ហាញថាគោលបំណងរបស់អាជ្ញាធរ គឺដើម្បីចង់គ្រប់គ្រងទាំងស្រុងលើអ្នករិះគន់"។

សង្គមស៊ីវិល មានការសោកស្តាយជាខ្លាំងចំពោះការចោទប្រកាន់ទាំងនោះ ហើយសូមសំណូមពរមេត្តាឲ្យមានការដោះលែងអ្នកទាំងប្រាំនាក់ឲ្យនៅក្រៅឃុំបណ្តោះអាសន្នរង់ចាំសវនាការ និងធានាជាថ្មីថា សិទ្ធិនិងសេរីភាពជាមូលដ្ឋាននានារបស់អ្នកការពារសិទ្ធិមនុស្សក្នុងការអនុវត្តការងាររបស់អ្នកទាំងនោះ ត្រូវបានអនុវត្តដោយសេរី ជៀសផុតពីការបំភិតបំភ័យនិងការដាក់ទណ្ឌកម្ម។ យើងខ្ញុំ ក៏សូមអំពាវនាវដល់ចៅក្រមស៊ើបសួរ សូមមេត្តាអនុវត្តការងារប្រកបដោយឯករាជ្យភាព។

*សេចក្តីថ្លែងការណ៍នេះត្រូវបានគាំទ្រដោយៈ*

1. ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)
2. សហគមន៍ដីធ្លីបឹងកក់
3. សហគមន៍បឹងត្របែក
4. សហគមន៍បុរីកីឡា
5. សហគមន៍បឹងប្រាំ
6. សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC)
7. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)
8. អង្គការអនាគតយុវជនអាស៊ាន (CamASEAN)
9. សមាគមអភិវឌ្ឍន៍ជីវភាពពលរដ្ឋកម្ពុជា
10. សម្ព័ន្ធសហជីពកម្ពុជា (CATU)
11. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
12. បណ្តាញកម្មករធ្វើការងារតាមផ្ទះកម្ពុជា (CDWN)
13. សហព័ន្ធសហជីពកម្មករវិស័យដឹកជញ្ជូនកម្ពុជា (CFSWF)
14. គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
15. សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា (CICA)
16. ប្រធានសមាគមគ្រូបង្រៀនឯករាជ្យ (CITA)
17. សមាគមកម្មករសេដ្ឋកិច្ចក្រៅប្រពន្ធ័កម្ពុជា (CIWA)
18. សហភាពការងារកម្ពុជា (CLC)
19. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
20. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលដើម្បីលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)
21. សហព័ន្ធសហជីពកម្មករវិស័យដឹកជញ្ជូនកម្ពុជា (CTSWF)
22. បណ្តាញយុវជនកម្ពុជា (CYN)
23. សង់ត្រាល់ (CENTRAL)
24. គ្រឹស្តបរិស័ទសម្រាប់យុត្តិធម៌សង្គម
25. សម្ព័ន្ធដើម្បីសុចរិតភាព និង គណនេយ្យភាពសង្គម (CISA)
26. សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
27. មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)
28. បណ្តាញកសាងសន្តិភាពសហគមន៍ (CPN)
29. អង្គការសមធម៌កម្ពុជា

30. អង្គការ FIDH នៅក្នុងក្របខណ្ឌនៃការអង្កេតសម្រាប់ការពារអ្នកការពារសិទ្ធិមនុស្ស
31. សហគមន៍បណ្តាញស្ត្រីអតីតតំបន់បឹងកក់
32. អង្គការ Forum Asia
33. អង្គការយេនឌ័រ និងអភិវឌ្ឍន៍នៅកម្ពុជា (GADC)
34. ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF)
35. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
36. បណ្តាញព្រះសង្ឃឯករាជ្យដើម្បីយុត្តិធម៌សង្គម (IMNSJ)
37. យុវជនជនជាតិដើមភាគតិច ឃុំប្រមេ ស្រុកត្បែងមានជ័យខេត្តព្រះវិហារ
38. សមាគម ឥន្ទ្រទេវី (IDA)
39. សហគមន៍ដីធ្លី ភូមិ១ ខេត្តព្រះសីហនុ
40. សហគមន៍ដីធ្លី ភូមិព្រែកជីក ខេត្តកោះកុង
41. លីកាដូ កាណាដា
42. សហគមន៍ឡពាង ខេត្តកំពង់ឆ្នាំង
43. អង្គការ មាតាធម្មជាតិ
44. អង្គការស្ពានសន្តិភាព (PBO)
45. សហគមន៍ភ្នំបាត
46. សហគមន៍ភូមិ ២៣
47. អង្គការពន្លកខ្មែរ
48. សហគមន៍ព្រែកតាគង់
49. សហគមន៍ព្រែកតាទ្ង
50. សមាគមធាងត្នោត (STT)
51. សហគមន៍ SOS ព្រលានយន្តហោះអន្តរជាតិភ្នំពេញ
52. អង្គការស្ត្រីខ្មែរ
53. សហគមន៍ថ្មគោល (TK)
54. សហគមន៍ទួលសង្កែ B
55. សហគមន៍ទំនប់ពីរ
56. អង្គការអភិវឌ្ឍស្ត្រីក្រីក្រទីក្រុង
57. បណ្តាញព្រះសង្ឃវត្តថាន់
58. អង្គការពិភពលោកប្រឆាំងនឹងអំពើទារុណកម្ម (OMCT) នៅក្នុងក្របខណ្ឌនៃការអង្កេតសម្រាប់ការពារអ្នកការពារសិទ្ធិមនុស្ស
59. អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)